**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០០៥/០៣/២០០៧ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧

**សូមជម្រាបមក**

**លោកជំទាវប្រធានគណៈកម្មការ**

**សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា**

**កម្មវត្ថុ** : សំណើសុំពិនិត្យធម្មនុញ្ញភាពពាក់ព័ន្ធករណីសមាជិករាជរដ្ឋាភិបាលបំពេញមុខងារជាសមាជិកក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ

**យោង** : លិខិតរបស់លោកជំទាវលេខ ១០៨/១១០៧ គ.ស.ប.អ.ព ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ផ្ញើមកក្រុមប្រឹក្សាធម្មនុញ្ញ តាមរយៈសម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកជំទាវប្រធានគណៈកម្មការថា ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យ ពិភាក្សាលើសំណើរបស់លោកជំទាវ ក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកសំណើរបស់ប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា មកពិនិត្យបានឡើយ ដោយម្ចាស់សំណើពុំមានគុណវុឌ្ឍិស្របតាមទម្រង់ ដែលមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ : " ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន តំណាងរាស្ត្រមួយភាគដប់ ឬ តុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ "។

សូមលោកជំទាវប្រធានគណៈកម្មការទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**